ការសំភាសន៏របស់អ្នកមីង ប៉រ ហេង

ក៖ អ្នកសំភាសន៏ឈ្មោះ កុសល្យ វឌ្ឍនៈនិមល ខ៖ អ្នកត្រូវគេសំភាសន៏ ប៉រ ហេង

ការសង្ខេបរបស់អ្នកមីង ប៉រ ហេង

(ការសង្ខែមពីខ្ញុំនិមលឃើញថាជីវិតរបស់គាត់គឺមានការតស៊ូខ្លាំងណាស់តែរាល់ថ្ងៃគាត់ក៏ដោកជ័យក្នុងជីវិតជងដែរ)

ក៖
អញ្ចឹងអើជាដំបូងខ្ញុំសូមអរគុណមីងដែលបានអនិញ្ញាត្តិអោយខ្ញុំមកសំភាសន៏មីងនៅថ្ងៃនេះហើយមីងខ្ញុំឈ្មោះកុសល្យវឌ្ឍនៈនិមលហើយជានាក់សំភាសន៏មីងថ្ងៃនេះហើយទីតាំងសំភាសន៏គឺនៅភូមិទ្រាពីសង្កាត់ស្ទឹងមានជ័យខណ្ឌមានជ័យក្រុងភ្នំពេញហើយថ្ងៃខែដែលសំភាសន៏គឺនៅថ្ងៃទី១៨ខែ១០ឆ្នាំ២០១៧ហើយអើការសំភាសន៏នេះគឺត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅសហរដ្ឋអាមេរិកដែរមានឈ្មោះថាBYUហើយគោលបំណងរបស់សាលារដើម្បីជួយប្រជាជនខ្មែរទាំងអស់គាត់អាចមានឱកាសថែរក្សារប្រវត្តិត្រួសាររបស់គាត់ហើយគាត់អាចផ្តល់ឱកាសដល់កូនចៅជំនាន់ក្រោយគាត់ដើម្បីពួកគាត់អាចមានឱកាសរៀនពីជីវិតរបស់មីងហើយនឹងអើអោយមនុស្សដទៃទៀតអាចមានឱកាសរៀនពីជីវិតរបស់មីងដែរណាមីងហើយមីងអើនៅពេលដែរខ្ញុំសំភាសន៏មីងហើយខ្ញុំហ្នឹងយកការសំភាសន៏នេះដាក់ចូលទៅក្នុងវេបសាយ៏មួយរបស់សាលារ BYUដែរមានឈ្មោះថាwww.cambodaioralhistrice.byu.edu
អញ្ចឹងតើមីងអញ្ញាត្តិដើម្បីអើអោយខ្ញុំយកការសំភាសន៏របស់មីងដាក់ចូលទៅក្នុងវេបសាយ៏ខ្ញុំហ្អេស?

ខ៖ អើមិនបាន។

ក៖ អញ្ចឹងមីងយល់ព្រមណា?

ខ៖ ចាស។

ក៖
ចាសអរគុណច្រើនមីង។ហើយអើអញ្ចឹងជាដំបូងខ្ញុំចង់សួរឈ្មោះមីងតើមីងមានឈ្មោះពេញនៅក្នុងអត្តសញ្ញាណបទឈ្មោះអីដែរ?

ខ៖ ឈ្មោះអើប៉រហេង។

ក៖ ប៉រហេង?ហើយអើមីងមានឈ្មោះហៅក្រៅហ្អេស?

ខ៖ មាន។

ក៖ ឈ្មោះអីគេមីង?

ខ៖ ឈ្មោះអើម៉ៅ។

ក៖ ឈ្មោះម៉ៅ?

ខ៖ ចាស។

ក៖ ឈ្មោះម៉ៅហ្នឹងគេហៅមីងតាំងពីក្មេងមកឬក៏ពេលធំហើយ?

ខ៖ ចាសតាំងពីក្មេង។

ក៖ ចាសមីង!ហើយអើមីងឆ្នាំនេះមីងមានអាយុប៉ុន្មានហើយ?

ខ៖ ខ្ញុំអាយុអើហាសិបហាសិបឆ្នាំ។

ក៖ ហាសិបឆ្នាំមីងណា?

ខ៖ ចាស។

ក៖ អញ្ចឹងតើមីងកើតនៅថ្ងៃណាខែណាឆ្នាំណាដែរ?

ខ៖ អើខ្ញុំកើតនៅឆ្នាំអើ១៩៦៣។

ក៖ ១៩៦៣?ចាសហើយចុះថ្ងៃ?

ខ៖ អត់ចាំហ្អេស។

ក៖ ខែក៏អត់ចាំដែរ?

ខ៖ អត់ទេ។

ក៖ ចាសហើយចុះមីងអើឆ្នាំមីងបើសិនគិតជាឆ្នាំខ្មែរឆ្នាំអីគេ?

ខ៖ ឆ្នាំឆ្នាំអើមមែ។

ក៖ ឆ្នាំមមែហ្នឹងសត្វពពែមីងណា?

ខ៖ ហ្នឹងហើយ។

ក៖ ចាសហើយអើចុះមីងចាំពីកន្លែងទីកំណើតរបស់មីងហ្អេសតើមីងកើតនៅណា?

ខ៖ ខ្ញុំកើតនៅអើ។

ក៖ ភូមិ?

ខ៖ ភូមិគគីងឃុំជាក្រាំងអើស្រុកព្រៃនប់ក្រុងព្រះសីហនុ។

ក៖ អញ្ចឹងមីងអ្នកស្រុកកំពង់សោមណា?

ខ៖ ហ្អឺ។

ក៖ ហើយអើសំរាប់មីងតើមីងមានបងប្អូនចំនួនមាណនាក់ដែរ?

ខ៖ បី។

ក៖ បីនាក់?

ខ៖ ចាស។

ក៖ អើប្រុសមាណស្រីមាណ?

ខ៖ ប្រុសពីស្រីមួយ។

ក៖ ចាស!ហើយមីងជាកូនទីមាណ?

ខ៖ កូនពៅ។

ក៖
ពៅគេស្រី។ហិហិហិហើយអើមីងអាចរៀបរាប់ឈ្មោះបងប្អូនរបស់មីងទាំងបីនាក់បានហ្អេស?

ខ៖ បាន។

ក៖ ចាស។

ខ៖ អើបងទីមួយគាត់ឈ្មោះអើដុំ។

ក៖ ឈ្មោះគាត់ពេញហ្អាស?
ខ៖ ឈ្មោះគាត់ពេញឈ្មោះដុំចឹងមក។

ក៖ ឈ្មោះដុំអញ្ចឹង?

ខ៖ ចាស។

ក៖ ដុំទទេ?

ខ៖ ចាស។

ក៖ ចាសហើយចុះអើបងទីពី?

ខ៖ បងទីពីឈ្មោះអើជាន់សុវន់។

ក៖ ជាន់សុវន់?

ខ៖ ចាស។

ក៖ ហើយចុះបង?ហើយបន្ទាប់មកបងស្រីឈ្មោះប៉ែរ?

ខ៖ ប៉ែរហេង។

ក៖ ប៉ែរហេង?

ខ៖ តែអើបងប្អូនខ្ចុំបីនាក់ដាក់ត្រកូលខុសគ្នារ។

ក៖ ចាសហ្នឹងហើយមិចអញ្ចឹងបង?

ខ៖
អត់ដឹងដែរបើខ្ចុំដាក់មុនខ្ចុំដាក់ឈ្មោះចឹងទៅហើយដល់ពេលគាត់ធ្វើក្រោយគាត់យកជីតារបស់គាត់ដាក់ខ្ចុំដាក់ឪពុក។

ក៖ អរអញ្ចឹងជ៉ាម៉ាក់បងនាក់ដាក់?

ខ៖ ចាស។

ក៖ ជ៉ាម៉ាក់មីងនាក់ដាក់ណា?

ខ៖ ចាស។

ក៖
ហើយសំរាប់មីងតើចាំសាច់រឿងអីខ្លះអំពីបងបអូនរបស់មីងនៅពេលដែរមីងនៅក្មេងហ្អេស?
ដូចជាមានអនុស្សាវរីយ៍អីខ្លះជាមួយគ្នារ?

ខ៖
មានអីមានតែគាត់ពីកាលនៅសម័យពលពតអញ្ចឹងគាត់នៅកងចំឡាត់នៅអីរៀងៗខ្លួនចឹង ដ៏ធំមកដឹងពលពតមង។

ក៖ អញ្ចឹងអត់សូវមានពេលនៅជាមួយគ្នារស្មិតស្នាល?

ខ៖
អត់ទេហើយដ៏ពេលរួចហើយក៏ខ្ញុំចឹងនៅកុមារចឹងទៅរែកដីរែកអីចឹងទៅដល់ពេល៧៩ហ្នឹងបានបានមកជួបគ្នារ។

ក៖ ចាសចាស។

ខ៖ ចាស។

ក៖ ហើយអើពេលមីងនៅក្មេងតើមីងចូលចិត្តលេងល្បែងប្រជាប្រិយ៍អីជាមួយពួកគាត់?

ខ៖ អត់ដែលបានលេងអីជាមួយគ្នារទេ។

ក៖ អរ!

ខ៖ ចាស!

ក៖ គីធ្វើការរហូត?

ខ៖ ធ្វើការរហូត។

ក៖ ចាស!

ខ៖ គ្មានពេលទំនេរទេរ។

ក៖ ចាស។

ខ៖
ធ្វើការអញ្ចឹងដល់ពេលអើខ្ញុំមកដល់៧៩ហ្នឹងខ្ញុំរៀនរៀនបានរៀនបានមាណប្រហែល១ខែក៏ម៉ែខ្ញុំចាស់ឈឺចាស់ចឹងក៏មកធ្វើស្រែរអត់បានរៀនហ្នឹងគេទេ។

ក៖ ចាស។

ខ៖ ធ្វើស្រែចញ្ចឹមម៉ែឪអញ្ចឹងទៅ។

ក៖ ចាស។

ខ៖
អីរហូតដល់ខ្ញុំហ្នឹងមកពីមកពីដើងគោរាលរេញហ្នឹងទៅនៅស្រុកវិញការប្តីឆ្នាំប៉ៃតបួនដើមប៉ៃតបួន។

ក៖ ចាស។

ខ៖ ហើយអញ្ចឹងហើយក៏មានគ្រួសារទៅ។

ក៖ ចាស។

ខ៖ អឺ!

ក៖ ហើយសព្វថ្ងៃមីងរស់នៅអើទីក្រុងភ្នំពេញនេះឬក៏នៅខេត្តក្រុងព្រះសីហនុ?

ខ៖ នៅក្រុងខេត្តក្រុងព្រះសីហនុ។

ក៖ ហ្អរចាសចាស។

ខ៖ អឺ។

ក៖
ហើយអើអើអញ្ចឹងមីងតើពេលនេះពួកគាត់រស់នៅកន្លែងណាដែរបងប្អូនរបស់មីងហ្អាសទាំងពីនាក់ហ្អាស?

ខ៖ បងប្អូនខ្ញុំខ្ញុំនៅស្រុកកំណើតខ្ញុំនៅនៅហ្នឹងស្រុកកំណើតមងហ្អាស។

ក៖ ចាសរស់នៅណាដែរសព្វថ្ងៃ?

ខ៖ ចាសតែអើបងខ្ញុំទីមួយហ្នឹងគាត់នៅថ្មសរ។

ក៖ ចាស។

ខ៖
តែដល់ពេលគាត់អត់មានការងាអីធ្វើទៅចាប់បង្អៀងចាប់ត្រីអីអត់បានក៏គាត់មករស់រស់នៅនៅស្រុកហ្នឹងនៅផ្ទះជួលគេ។

ក៖ អរចាសនៅជាមួយប្រពន្ធគាត់ណា?

ខ៖ ចាសហ្នឹងនៅជាមួយប្រពន្ធគាត់ហ្នឹងនៅផ្ទះជួលនៅផ្ទះជួលជួលផ្ទះគេនៅហ្អាស។

ក៖ ចាស!

ខ៖ ចាសគាត់មានការលំបាកខ្លាំងណាស់។

ក៖ ចាសហើយអើចុះបងមួយទៀត?

ខ៖ បងមួយទៀតនៅស្រុកគេ។

ក៖ នៅស្រុកណាបង?

ខ៖ ហ្នឹងឪអាគ្រាហ្នឹងនៅញ៉ូសាលែន។

ក៖ អរនៅញ៉ូសាលែនចាស។

ខ៖ ចាស។

ក៖ ហើយពួកគាត់រាល់ថ្ងៃអើប្រកបមុខរបរអីគេដែរ?

ខ៖ ខ្ញុំហ្អាស?

ក៖ ពួកគាត់ទាំងអស់គ្នារហ្អាស?

ខ៖ ខ្ញុំអើយប្តីខ្ញុំលាងម៉ូតូខ្ញុំអើយលក់តវ៉ាន់ចាប់ហួយតិចតួចនៅផ្ទះ។

ក៖ ហើយចុះបងប្រុសមីង?

ខ៖ បងប្រុសខ្ញុំគាត់ធ្វើអើសំណង់។

ក៖ ហើយចុះបងមួយទៀត?

ខ៖ បងមួយទៀតហ្នឹងដឹងគាត់ធ្វើអីខ្ញុំអត់ដឹងដែរ។

ក៖ ហិហិហិហិចាសហើយអើសំរាប់មីងតើម្តាយរបស់មីងឈ្មោះអីគេដែរ?

ខ៖ ម្តាយខ្ញុំឈ្មោះអើនាង។

ក៖ ឈ្មោះអីគេនាង?

ខ៖ កុយនាង។

ក៖ កុយនាង?ចុះឪពុក?

ខ៖ ឪពុកឈ្មោះប៉របៃ។

ក៖ ប៉របៃ?

ខ៖ ចាស។

ក៖ ចាសហើយបើគិតមកដល់ឥឡូវពួកគាត់មានអាយុមាណហើយមីង?

ខ៖ គិតមកដល់ឥឡូវអាយុប្រហែលខ្ទង់ជាប៉ែតកៅអីដឹង។

ក៖ អរចុះ?

ខ៖ តែគាត់ស្លាប់អស់ហើយ។

ក៖ ស្លាប់ទាំងពីចាស។

ខ៖ ចាស!

ក៖ ហើយគាត់អាយុច្រើនៗហើយដែរ?

ខ៖ ចាស!

ក៖ ចាស!ហើយអើនាក់មីងដឹងថាពួកគាត់កើតនៅថ្ងៃណាខែណាឆ្នាំណាហ្អែស?

ខ៖ ខ្ញុំអត់ដឹងទេអូន។

ក៖ អញ្ចឹងហ្អរ?

ខ៖ ចាស!

ក៖ ប្រហែលប្រហែលក៏អត់ដឹងដែរណា?

ខ៖ ចាសអត់ដឹងទេ។

ក៖ ហើយចុះដឹងពីកន្លែងកំណើតរបស់គាត់ហ្អែស?

ខ៖ ទីកន្លែងកំណើតគាត់នៅនៅភូមិបាគោកឃុំបាត្រាំងស្រុកព្រៃបន្ទប់ហ្នឹង។

កៈ នៅហ្នឹងទាំងពី?

ខៈ ចាសនៅទាំងពី។

កៈ
អរចាស!ហើយអើចុះតើមីងដឹងថាអឹមឪពុករបស់មីងគាត់អើប្រកបមុខរបរអីគេដើម្បីចញ្ចឹមជីវិតរបស់គាត់ហ្អាស?

ខៈ ធ្វើស្រែអូន។

កៈ អរគាត់នាក់ធ្វើស្រែចំការណា?

ខៈ ចាសនាក់ស្រែចំការ។

កៈ
ហើយចុះអើឪពុករបសមីងគាត់ជាមនុស្សមិចដែរ?គាត់ជាមនុស្សដែរស្លូតឬក៏មនុស្សកាច?

ខៈ ស្លូត។

កៈ ស្លូត?

ខៈ ចាស។

កៈ ចាស។

ខៈ ម៉ែឪខ្ជុំស្លូតៗណាស់។

កៈ ចាសហើយចុះអើម្តាយរបស់មីងគាត់ប្រកមមុខរបរអីគេដែរ?

ខៈ ធ្វើស្រែចំការដូចតែគ្នារហ្នឹង។

កៈ ដូចគ្នារ។

ខៈ ចាស។

កៈ ហើយគាត់ជាមនុស្សបែបណាដែរ?

ខៈ គាត់ស្លូតដូចតែគ្នារ។

កៈ គាត់ស្លូតដូចគ្នារហិហិហិហិ។

ខៈ ចាសចាស។

កៈ ចុះមីងអត់ត្រូវអត់ដែរត្រូវគាត់រៃហិហិហិហិ។

ខៈ ចាសរៃដែរធម្មតាយើងកូនខុសអញ្ចឹងម៉ែឪរៃតិចតួចអីចឹងណា។

កៈ ចាសចាស។

ខៈ មិនទៅរៃអីក៏ធ្ងន់ធ្ងរហ្អេស។

កៈ
ចាសចាសហើយចុះអើតើមីងនៅចងចាំសាច់រឿងអីខ្លះអំពីពួកគាត់ហ្អេស?ថាតើមីងធ្លាប់មានអនុស្សាវរីយ៍អីជាមួយហ្នឹងឪពុកម្តាយមីងអញ្ចឹងហ្អាសណា?

ខ៖ មានតែគាត់ខ្លុំគាត់ចាស់ទៅយើងរកស៊ីចញ្ចឹមគាត់ហ្នឹង។

ក៖ ចាស។

ខ៖ មើលថែគាត់ដល់តែគាត់ស្លាប់ចឹងទៅ។

ក៖ ចាស។

ខ៖ ចាសគាត់រង្វេងម៉ែខ្លុំរង្វេង៧ឆ្នាំ។

ក៖ អរគាត់មានជំងឺណាមីងណា?

ខ៖
គាត់ដូចថាអត់ឈឺអីទេគាត់ចេះតែរង្វេងចឹងរង្វេងគាត់អត់ដឹងចឹងបើឪពុកខ្លុំគាត់ឈឺគាត់ឈឺមង។

ក៖ ចាស។

ខ៖
ចាស។ឈឺដំបូងគេថាគាត់របេងដល់ពេលអោយពេទ្យមើលអីចឹងទៅជាទៅប៉ុន្តែគាត់នៅតែនេះនេះថាគេហៅថាកើតអ៊ុតស្វាយពីដើមហ្អស។

ក៖ ចាស។

ខ៖ កើតអ៊ុតចឹងវាស៊ីអាដៃហ្នឹងឡើងស្ងិតមួយចំហៀងចឹងទៅ។

ក៖ អរ។

ខ៖
ដល់ពេលអញ្ចឹងទៅវានេះទៅវាស៊ីសួតស៊ីអីគាត់ចឹងហ្អសមិនមែនរបេងហ្អេសអាហ្នឹងអាជំងឺរោគពីដើមហ្នឹងវាស៊ីហ្អស។

ក៖ ចាស។

ខ៖
ចាសដល់ពេលចឹងគាត់ទ្រុតទ្រោមកំលាំងចឹងគាត់ដូចថាដល់គាត់ចាស់ចឹងទៅគាត់ដើរអីអត់រួចចឹងនៅដេកមួយកន្លែង។

ក៖ ចាសចាស។

ខ៖ អញ្ចឹងយើងមានតែថែមើលគាត់ចឹងទៅ។

ក៖ ចាសចាស។

ខ៖ ចាស។

ក៖
ចាសហើយអើសំរាប់មីងតើអើឪពុកម្តាយរបស់មីងគាត់ធ្លាប់ប្រាប់អីខ្លះអំពីជីវិតរបស់ពួគាត់នៅពេលដែរពួកគាត់នៅក្មេងហ្អស?

ខ៖ អត់មានគាត់គ្រាន់តែនិយាយថាគាត់ពិបាកចឹងហ្អសគាត់ពិបាកគាត់ក្រចឹងហ្អស។

ក៖ ចាស។

ខ៖ គាត់ក្រគាត់អត់គាត់អីអញ្ចឹងគាត់រកស៊ីតែចាស់ពីដើមកាប់ផ្តៅកាប់អីហ្នឹង។

ក៖ ចាសចាស។

ខ៖ ហ្នឹងហើយ។

ក៖ តាំងពីក្មេងៗ។

ខ៖ ហ្នឹងហើយគាត់មានតែប៉ុណ្ណឹង។

ក៖ ចាស។

ខ៖
ហើយគាត់ថាអោយយើងប្រឹងប្រែងប្រឹងរកខំប្រឹងសន្សំអីចឹងទៅកុំអោយដូចគាត់ចឹងហ្អាស។

ក៖ ចាសចាស។

ខ៖អឺ!

ក៖
ហើយចុះអើមីងនៅចងចាំឈ្មោះរបស់ជីដូនជីតារបស់មីងទាំងខាងម្តាយទាំងខាងឪពុកហ្អែស?

ខ៖ អឺៗមើលជីដូនខ្ញុំខាងឪពុកឈ្មោះអើយយាយសុក។

ក៖ ចុះជីតា?

ខ៖ អើជីតាខ្ញុំឈ្មោះតាជាន់។

ក៖ តាជាន់?

ខ៖ ចាស។

ក៖ ចុះខាងម្តាយ?

ខ៖ ខាងម្តាយអើយតាឈ្មោះកុយអើម្តាយគាត់ឈ្មោះយាយហាប់។

ក៖ យាយហាប់។

ខ៖ ចាស។តែត្រកូលគាត់អីខ្ញុំអត់ស្គាល់ទេ។

ក៖ ចាសអត់អីហិហិហិ។

ខ៖ ស្គាល់តែប៉ុណ្ណឹង។

ក៖ ចុះមីងអើដឹងថ្ងៃខែឆ្នាំកំណើតដែរពួកគាត់កើតនឹងទីកន្លែងដែរពួកគាត់កើតហ្អែស?

ខ៖ ពួកគាត់កើតទីកន្លែងគាត់កើតនៅស្រុកកំណើតហ្នឹងជាមួយគ្នារហ្នឹងទាំងអស់។

ក៖ នៅភូមិ?

ខ៖ ភូមិគោយុំជាស្រាំងស្រុកព្រៃនប់។

ក៖ ខេត្ត?ក្រុងព្រះសីហនុ?

ខ៖ ក្រុងព្រះសីហនុ។

ក៖ ចាសហើយអើថ្ងៃខែគាត់អត់ចាំទេ?

ខ៖ អត់ចាំទេ។

ក៖ ចាសហើយអើតើមីងធ្លាប់ដឹងរឿងអីខ្លះអំពីប្រវត្តិរបស់ជីដូនជីតារបស់មីងហ្អាស?

ខ៖ អត់។

ក៖ ឪពុកម្តាយមីងអត់ដែរប្រាប់ទេណា?

ខ៖ អត់ទេ។

ក៖ អត់សោះមង?

ខ៖ គាត់គ្រាន់តែថាម៉ែឪគាត់ក្រតែប៉ុណ្ណឹងហ្នឹងឯង។

ក៖ ចាសចាស។

ខ៖ ម៉ែឪគាត់ក្រគាត់ហត់ធ្វើស្រែចឹងទៅណាចាស់ពីដើម។

ក៖ ចាស។

ខ៖ មានធ្វើអីមានតែកាប់ស្មារធ្វើស្រែធ្វើចំការចឹងទៅណា។

ក៖
ចាសអញ្ចឹងមីងសុំសួរតិចអញ្ចឹងអើថ្ងៃហ្នឹងមីងនៅភ្នំពេញប៉ុន្តែមីងមិនមែនរស់នៅទេគ្រាន់តែមកលេងឬមួយមកមិចម៉ិញ?

ខ៖ មកជូនដំណើរក្មួយឡើងកាប៉ាល់ហោះទៅវិញ។

ក៖ អរហើយបន្ទាប់មកមីងនឹងទៅខេត្តក្រុងព្រះសីហនុវិញណា?

ខ៖ អឺ!

ក៖ អញ្ចឹងអើតើមីងរស់នៅក្រុងព្រះសីហនុរយៈពេលប៉ុន្មានឆ្នាំហើយ?

ខ៖ នៅយូហើយនៅអើយនិយាយរួបនៅតាំងពីក្មេងមកម្លេះ។

ក៖ តាំងពីក្មេងមក៥០ឆ្នាំហើយចឹង?

ខ៖ ចាស។

ក៖ អរអញ្ចឹងអត់ផ្លាស់ប្តូរដំបូនសោះ?

ខ៖ ចាស។

ក៖
អូយនៅបានយូហ្អាសហិហិហិ។ហើយអើតើមីងមានសាច់ញាតិណាផ្សេងទៀតដែររស់នៅក្រៅប្រទេសអើខុសពីអើស្រុកខ្មែរហ្អេស?

ខ៖ មានតើ។

ក៖ ចាសហើយគាត់ឈ្មោះអីគេ?

ខ៖ មាននៅឈ្មោះអើយអីទេរើយអីគាត់ឈ្មោះគាត់ឈ្មោះកំណើតគាត់ឈ្មោះយេន។

ក៖ យេនចាស។

ខ៖ ចាសដល់ពេលគាត់អើដល់ពេលសព្វថ្ងៃនេះគាត់ដាក់ឈ្មោះគាត់កែវសីម។

ក៖ កែវសីម?

ខ៖ ចាស។

ក៖ ចាសគាត់នៅកន្លែងណាដែរ?

ខ៖ គាត់នៅអើយប្រទេសកាណ្ណាដា។

ក៖ គាត់នៅកាណ្ណាដា?

ខ៖ ចាស។

ក៖ ស្គាល់រដ្ឋហ្អែស?ស្គាល់ដំបនទេ?

ខ៖ អត់ទេអូនអត់ទេអត់។

ក៖ ស្គាល់តែប្រទេសណា?

ខ៖ ចាស។

ក៖ ហើយអើសំរាប់ស្វាមីមីងវិញតើគាត់ឈ្មោះអីគេដែរ?

ខ៖ ចាន់ណែម។

ក៖ ចាន់ណែម?

ខ៖ ចាស។

ក៖ ចាសហើយអើតើមីងរៀបអាពាហ៍ពិពាហ៍នៅពេលណាដែរ?

ខ៖ ខ្ញុំរៀបអើនៅឆ្នាំ៨៤។

ក៖ ថ្ងៃទីមាណខែមាណ?

ខ៖ អើដឹងថ្ងៃទីមាណខែមាណទេរើយភ្លេចអស់ហើយ។

ក៖ អត់ចាំតែដឹងថាឆ្នាំ១៩៨៤ណា?

ខ៖ ចាស។

ក៖
ចាសហើយអើសំរាប់អាពាហ៍ពិពាហ៍របស់មីងគឺត្រូវបានរៀបចំឡើងដោយឪពុកម្តាយឬក៏មីងរៀបចំវាដោយខ្លួនឯង?

ខ៖ ឪម្តាយ។

ក៖ អញ្ចឹងឪពុកម្តាយមីងរៀបចំអោយណា?

ខ៖ ចាស។

ក៖
ចាសអញ្ចឹងមីងអើតើមីងអាចប្រាប់ខ្ញុំបានហ្អេសអំពីមូលហេតុដែរមីងស្គាល់គ្នាជាមួយហ្នឹងស្វាមីហ្អស?តើជួបគ្នានៅកន្លែងណាហេតុបានរៀបការជាមួយគ្នាស្រឡាញ់គ្នាចឹងហ្អសណា?

ខ៖ ហិហិហិហិពិបាកដល់ហើយដ៏ចឹង។

ក៖ អត់ចាំហ្អា?

ខ៖
ខ្ញុំអត់ដែរស្រឡាញ់គ្នាអីផងប៉ុន្តែគ្រាន់តែថាគាត់នៅស្រុកភូមិជាមួយគ្នាអីចឹងដល់ពេលហើយយើញគ្នាគាត់តាមរយៈម៉ែឪ។

ក៖ អរចាស់ចាស់។

ខ៖ ចាសចាស់ចាស់។

ក៖ គាត់ចូលស្តីដណ្តឹងមីង?

ខ៖ ចាសចូលស្តីយើងអញ្ចឹងទៅយើងតាមម៉ែតាមឪទៅ។

ក៖ អត់ដឹងមូលហេតុថាហេតុអីបានជាគាត់ស្រឡាញ់យើងនៅពេលយើងទៅធ្វើអីអីណា?

ខ៖ អត់អត់ដឹងទេ។

ក៖
ហិហិហិហិហើយចុះមីងមានទទួលបានថ្ងៃជំនូនហ្អេស?ឥឡូវគេហៅសម័យឥឡូវគេហៅថ្លៃទឹកដោះហ្អស?

ខ៖ បានតើ។

ក៖ អញ្ចឹងអរ?

ខ៖ ចាស។

ក៖ លោកពូកាលពីសម័យរបស់មីងគេអោយជាលុយឬក៏ជារបស់?

ខ៖ លុយ។

ក៖ ជាលុយសុទ្ធឬក៏?

ខ៖ លុយតែគ្រាន់តែថាកាលជំនាន់ខ្ញុំការរាលុយថ្លៃណាអូនណា។

ក៖ ចាស។

ខ៖ តែពីបីពាន់អីទិញឥវ៉ាន់ការមិនអស់ទេ។

ក៖ ចាស។

ខ៖ ពីបីលុយខ្មែរយើងហ្នឹងហ្អស។

កៈ ចាសចាសចាស។

ខៈ ចាសហ្នឹងដល់ចឹងម៉ែខ្ញុំហ្នឹងគាត់ស៊ីថ្លៃទឹកដោះអឺម៧០០០។

កៈ អរ។

ខៈ ហើយដល់ពេលគាត់ការយកមកការចឹងហ្នាស។

កៈ ចាសចាស។

ខៈ ទិញរបស់របរសំភារៈការទៅ។

កៈ ចាសចាសហើយអើមីងចេះអានភាសារខ្មែរនឹងសរសេរនឹងនិយាយបានល្អប៉ុនណាដែរ?

ខៈ ខ្ញុំអត់ចេះអក្សរទេ។

កៈ ភាសារខ្មែរហ្អរ?

ខៈ ចាស។

កៈ ចាសចាសចុះមីងចេះភាសារផ្សេងខុសពីភាសារខ្មែរហ្អេស?

ខៈ អត់ទេហិហិហិ។

កៈ អត់ចេះដូចគ្នារ?

ខៈ ចាស។

កៈ ចាសចាសអញ្ចឹងមីងរៀនបានត្រឹមថ្នាក់ទីមាណដែរ?

ខៈ ខ្ញុំរៀនបានត្រឹមថ្នាក់ទីបី។

កៈ ទីបីពីមុន?

ខៈ ទីបីខ្មែរយើងពីដើម។

កៈ ហើយមីងរៀននៅសាលារណាដែរ?

ខៈ ខ្ញុំអើយរៀននៅកាលហ្នឹងរៀននៅវាលរេញ។

កៈ រៀននៅជើងគោ?

ខៈ ចាសរៀននៅជើងគោ។

កៈ ខ្ញុំស្គាល់សាលារហ្នឹងហិហិហិហិហាស្គាល់ច្បាស់មងសាលាហ្នឹង។

ខៈ ហ្នឹងហើយអូនឯងធ្លាប់នៅហ្នឹងហ្អា?

កៈ ចាស។

ខៈ ហ្អឺ!

កៈ
អើគាត់ខ្ញុំមានអ៊ុំគាត់នៅហ្នឹងហ្អរហើយខ្ញុំទៅលេងរហូតបងស្រីខ្ញុំគាត់រៀននៅសាលាជើងគោខ្ញុំគ្រាន់តែទៅលេង។

ខៈ
ហ្នឹងហើយខ្ញុំរៀននៅហ្នឹងរៀនបើថាទៅខ្ញុំរៀនបានត្រឹមថ្នាក់ទីបីអីក៍ដូចថាវារៀនមិនចូលហ្អាសវាការឹកវារាច្រើនពេកមើលក្របីផងក្លួយផងអីចឹងហ្អាណា។

កៈ ចាសចាស។

ខៈ
ហើយណាម៉ែឪចាស់ផងអញ្ចឹងទៅមើលថែជំងឺគាត់ផងអីផងរៀនអត់ចូលឈប់រៀនមងទៅ។

កៈ ហ្អរចាស។

ខៈ ចាស។

កៈ
ចាសហើយអើតើមីងមានមិត្តភក្រ័ណាស្និតស្នាលដែរមីងបានធំធាត់ឡើងមកជាមួយគ្នារហ្អេស?

ខៈ អត់ទេអត់ចេះមានមិត្តភក្រ័អីផង។

កៈ អត់មានសោះ?

ខៈ ចាស៕

កៈ ចាសហើយអើមីងេជានាក់ធ្វើស្រែចំការមែន?

ខៈ ចាស។

កៈ អញ្ចឹងមីងជានាក់ស្រែចំការណា?

ខៈ ចាស។

កៈ ហើយហើយមីងធ្លាប់មានអើអាជីវកម្មជាលក្ខណៈគ្រួសារហ្អេស?

ខៈ អាជីវកម្មលក្ខណៈគ្រួសារមានតែការលក់ដូរកស៊ី។

កៈ រាល់ថ្ងៃហ្នឹងមីងណា?

ខៈ ចាសចាស។

កៈ អរចាសមីងលក់អីគេខ្លះទៅ?

ខៈ មីងលក់ឥវ៉ាន់ដូចជាបន្លែមួយមសាច់អីហ្នឹង។

កៈ អរលក់របស់ញ៉ាំស្រស់ផងហើយហ្នឹងរបស់គ្រឿងកំពង់ផង។

ខៈ ចាស។

ក៖
ចាសចាសហើយអើសំរាប់មីងតាំងពីមីងនៅក្មេងមកដល់ឥឡូវតើមីងបានធ្វើការងារអីខ្លះដើម្បីរកប្រាក់កំរៃចិញ្ចឹមជីវិតហ្អាស?

ខ៖ មានរកអីមានតែយើងធ្វើស្រែធ្វើអីចឹងបានស្រូវលក់ជូនរដ្ឋទៅក៏ជំនាន់ចឹង។

ក៖ ចាសចាស។

ខ៖ ចាស។

ក៖
ហើយអើតាំងពីក្មេងរហូតមកដល់ពេលនេះតើមីងឃើញថាជីវិតរបស់មីងបានមានការផ្លាស់ប្តូរអីខ្លះហ្អេស?

ខ៖ មានតើ។

ក៖ ចាសឃើញអីគេខ្លះ?

ខ៖
កាលពីមុនខ្ញុំអត់ចឹងទៅធ្វើតែស្រែចំការតែឥឡូវខ្ញុំដូចថាយើងគ្រាន់តែវាបានថារីកចំរើនរឿងយើងរកស៊ីចឹងបានលុយបានកាក់អីចឹងគ្រាន់អោយកូនរៀនកូនសូត្រអីទៅ។

ក៖ ចាសមីងចាស។អញ្ចឹងវាធូស្រាលជាងមុនណាមីងណា?

ខ៖ ចាស។

ក៖ ហើយអើតើមីងចូលចិត្តញ៉ាំម្ហូបអីគេជាងគេ?

ខ៖ ហិហិហិញ៉ាំញ៉ាំម្ហូបដឹងញ៉ាំម្ហូបអីទេរើយខ្ញុំ។

ក៖ ញ៉ាំចូលចិត្តញ៉ាំទាំងអស់ហិហិហិ?

ខ៖ ចូលចិត្តតើហិហិហិចូលចិត្តតែផ្អក់មាំហិហិហិ។

ក៖ អរប្រភេទគ្រឿងផ្អាំ៕

ខ៖ ចាស។

ក៖ ចាសហើយចុះមីងចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេខ្លះជាងគេ?

ខ៖ អត់ចូលចិត្ត។

ក៖ អត់ចូលចិត្តលេង?

ខ៖ ចាស។

ក៖ ចុះអត់ចូលចិត្តមើលហ្អេស?

ខ៖ មើលដឹងមើលអីមើលអត់សូវជំណូលហិហិហិ។

ក៖
ចុះអើទាក់ទងជាមួយចម្រៀងវិញតើមីងមានចម្រៀងណាដែរមីងនៅតែចងចាំនៅពេលដែរមីងរៀននៅពីក្មេងហ្អេស?

ខ៖ អត់ចេះទេអត់ចេះច្រៀងចេះអីហ្នឹងគេទេ។

ក៖ ហើយចូលចិត្តស្តាប់អត់?

ខ៖ ស្តាប់បើបទណារៀងពិរោះទៅចេះស្តាប់បើបទណាអត់ពិរោះស្តាប់។

ក៖ ចូលចិត្តបទសម័យឪក៏បុរាណ?

ខ៖ ហិហិចូលចិត្តបទបុរាណ។

ក៖ បទរបស់អើលោកតាសុនស៊ីសាមុតអីណាមីងណា?

ខ៖ អឺ!

ក៖
ហិហិចូលចិត្តបទពីដើម!ហើយអើនៅក្នុងក្រុមគ្រួសារមីងតើមីងមានអើនាក់ណាគេដែរចេះលេងឌីបកណារភ្លេងហ្អែស?

ខ៖ អត់ផងៗ

ក៖ អត់មាននាក់ចេះលេងភ្លេងទេណាមីងណា?

ខ៖ ចាសអត់ទេ។

ក៖
អរចាសហើយចុះមីងអើតាំងពីមីងនៅក្មេងរហូតមកដល់តលូរតើផ្ទះរបស់មីងដែរមីងរស់នៅហ្នឹងមានលក្ខណៈមិចដែរ?ជាផ្ទះថ្មឬផ្ទះឈើផ្ទះស្បោផ្ទះស្លឹក?

ខ៖ ខ្ញុំពីមុនខ្ញុំនៅឈើ។

ក៖ ចាស។

ខ៖ ផ្ទះឈើប្រក់ស្លឹក។

ក៖ អរ!

ខ៖
តែសព្វថ្ងៃនេះខ្ញុំអើយយើងនេះចឹងទៅយើងបានលុយខ្លះទៅខ្ចីលុយរដ្ឋខ្លះទៅយកមកធ្វើផ្ទះជួលផងផ្ទះនៅផងធ្វើថ្មក្រោឈើលើ។

ក៖ ចាស។

ខ៖ ចាសយើងធ្វើផ្ទះល្វែងជួលអោយកម្មករនៅ។

ក៖
ចាសមីងហើយចុះអើផ្ទះហ្នឹងតើមីងបានសាងសង់វាដោយខ្លួនឯងឪក៏មីងបានជួយវាធ្វើឪក៏ជួលជាងទាំងអស់មង?

ខ៖ ជួលជាងទាំងអស់អូន។

ក៖ អរជួលជាងទាំងអស់មងមីងណា?

ខ៖ ចាសចាស។

ក៖ អញ្ចឹងមីងអើដឹងថាផ្ទះហ្នឹងត្រូវការសំភារៈអីខ្លះដើម្បីធ្វើហ្អេស?

ខ៖ អើដឹងសំភារៈអីខ្លះទេ។

ក៖ ដូចឥដ្ឋស៊ីម៉ង់?

ខ៖ ឥដ្ឋស៊ីម៉ង់។

ក៖ ខ្សាច់?

ខ៖ ខ្សាច់អីចឹងទៅដែកអីចឹងទៅ។

ក៖ ចាសចាស។

ខ៖ ចាស។

ក៖
ចាសហើយអើតើមីងមានជំនាញអីខ្លះដែរត្រូវបានបន្តវេនមកពីត្រួសារមីងហ្អេស?មានជំនាញចេះមកពីត្រួសារហ្អេស?

ខ៖ អត់ដឹងចេះរឿងអីទេ។

ក៖ អត់មាន?

ខ៖ មានតែចេះរកស៊ីលក់ដូប៉ុណ្ណឹង។

ក៖ ចាសមានតែប៉ុណ្ណឹងទេ។ចុះរាល់ថ្ងៃមីងអត់ធ្វើស្រែចំការទេហ្អា?

ខ៖ អើធ្វើប៉ុន្តែស្រែហ្នឹងវាធ្វើតែឯងធ្វើវាមិនបាន។

ក៖ ចាស។

ខ៖ ស្រែមានធ្វើប៉ុន្តែគេគ្រប់គ្នារគេអត់ធ្វើយើងធ្វើតែឯងវាធ្វើអត់ឈ្នះសត្វ។

ក៖ ចាសអរគ្រូវហើយៗ។

ខ៖ ចាស។

ក៖
ហើយមីងអើមីងអាចប្រាប់ខ្ញុំបានទេអំពីជីវិតអើពេលវេលាដែរលំបាកបំផុតនៅក្នុងជីវិតមីងហ្អាស?

ខ៖
ហ្នឹលំបាកបំផុតវាមានតែរឿងពីមុនមកយើងរកស៊ីអត់ដូចថាយើងក្រយើងអត់ចេះរត់រកទិសដៅរុលរកកន្លែងទិសដៅរកស៊ីចញ្ចឹមកូនចញ្ចឹមអីចឹងហ្អាស។

ក៖ ចាស។

ខ៖
ចាសវាលំបាកដែរហ្នឹងហ្អាសវាមិនជាមិនមិនជាមានបានអីទេទើបតែមកឥឡូវដ៏កូនធំៗអស់ទៅហ្នឹងខ្ចីរកស៊ីបានខ្លះទៅយកលុយគេខ្លះទៅអីខ្លះទៅបានលុយធ្វើផ្ទះធ្វើអីហ្នឹង។

ក៖ ចាសមីង។

ខ៖ ចាស។

ក៖ ប៉ុន្តែមីងបានឆ្លងកាត់វាមកបានយ៉ាងមេចដែរ?ដោយសារមីងខំប្រឹងឬក៏មេច?

ខ៖ ខំប្រឹងខំប្រឹងយើងរាល់ថ្ងៃខំប្រឹងខំសន្សំ។

ក៖ ចាស។

ខ៖
ហ្នឹងហើយយើងខំធ្វើពីកាងារនេះការងារនោះដើម្បីបច័យអើយយកអើប្រាក់មកសំរាប់ការសាងក្នុងគ្រួសារអញ្ចឹងហ្អស។

ក៖ ចាសមីងចាស។

ខ៖ ចាស។

ក៖ ចាសហើយធ្វើអោយមីងធូស្រាលដល់សព្វថ្ងៃនេះណា?

ខ៖ ចាសហើយកូនធ្វើការរោងចក្រខ្លះទៅ។

ក៖ ចាស។

ខ៖ ដើម្បីយកបរិការហ្នឹងយកមកផ្គត់ផ្គង់ក្នុងគ្រួសារ។

ក៖ ចាសមីងចាស។

ខ៖ ចាស។

ក៖
ហើយអើតើមីងមានពេលវេលាណាដែរមីងសប្បាយជាងគេនៅក្នុងជីវិតមីងហ្អែស?ដូចជាពេលដែរមីងរៀបការឬក៏អញ្ចឹងហ្អស?

ខ៖
ហិហិហិហិហិរៀបការដឹងរកកន្លែងណាសប្បាយទេអត់ចង់ផងហិហិហិដឹងសប្បាយមេចឃើញបើហត់យ៉ាងនេះហ្អរ។

ក៖ ហិហិហិហិអត់រំភើបដោយសារមីងជិតបានស្វាមីអីចឹងហ្អស?

ខ៖ អត់ដែរអត់ដឹងដូចក្មេងឥឡូវទេខ្ចុំជំនាន់ខ្ចុំហ្អរ។

ក៖ អញ្ចឹងហ្អរ?

ខ៖ ចាសម៉ែអោយការភ័យយំស្រែកចង់ងាប់ហើយមិនទាំងហ៊ានមើលមុខគ្នារផងៗ។

ក៖ អញ្ចឹងហ្អស?

ខ៖ មិនមែនដូចក្មេងឥឡូវបានស្រឡាញ់គ្នារមុនអីដឹងពីរឿងរាវចេះចោះអីអត់អត់សោះ។

ក៖ ហិហិហិហិមែនតើគាត់ឆ្លាតឆ្លាតហ្អសហិហិហិ។

ខ៖ ចាសក្មេងឥឡូវឆ្លាតណាស់។

ក៖
អញ្ចឹងអើសំរាប់មីងតើតាំងពីនៅក្មេងរហូតមកដល់ឥឡូវតើមីងធ្លាប់មានក្តីស្រមៃឬក៏មីងចង់បានអ្វីនៅក្នុងជីវិតរបស់មីងនៅពេលអនាគត់ហ្អេស?

ខ៖ អីមិនចង់តែមិនដឹងធ្វើមេចបាន។

ក៖ ចាសតើមីងចង់បានអីគេខ្លះ?

ខ៖ ហិហិហិ។

ក៖ ចង់ដូចចង់មានក្តីស្រមៃអីចឹងហ្អាស?

ខ៖ ដូចចង់យើងថាយើងចង់មានបានចឹងទៅអោយវាល្អមើលហ្នឹងគេចឹងហ្អាស។

ក៖ ចាស។

ខ៖ តែវាយើងវាធ្វើមិនបានដូចគេយើងបានត្រឹមតែស្រមៃតែយើងវារកវាមិនបាន។

ក៖ ចាស។

ខ៖ ចាស។

ក៖ ប៉ុន្តែអើរាល់ថ្ងៃមីងក៏ក៏មានអាជីវកម្មមួយណាមីងណា?

ខ៖ ចាស។

ក៖ ក៏ល្អដែរហិហិហិ។

ខ៖ ចាស។

ក៖
ចុះអើពេលមីងនៅក្មេងមីងចង់ធ្វើជាអីគេដែរ?ដូចជាចង់ធ្វើជាគ្រូរឬក៏ចង់ធ្វើជាពេទ្យអីហ្អេស?

ខ៖ ចង់ធ្វើពេទ្យដែរប៉ុន្តែយើងរៀនវាមិនចេះបានអីធ្វើហិហិហិ។

ក៖ ហ្អរចាសហ្អរ។

ខ៖
វានិយាយរួមទៅវាការវាសួកស្មាញពេកបានរៀនវាមិនចេះបើធំមកដឹងតែពីលំបាករហូតអត់ដែរមានសេចក្តីសុកក្តីសប្បាយហ្នឹងគេសោះ។

ក៖ ចាសមីង។

ខ៖
ចាសមានតែធំមកមានតែម៉ែឪចាសរកធ្វើស្រែចំការចញ្ចឹមគាត់រកស៊ីចញ្ចឹមគាត់រហូតដល់តែមានគ្រួសារក៏នៅតែពិបាក។

ក៖ ចាស។

ខ៖ ចាស។

កៈ
ចាសហើយចឹងមីងអើជាចុងក្រោយបើសិនជាតើមីងអើមានអីដើម្បីចង់ផ្តែផ្តាំដល់កូនចៅជំនាន់ក្រោយរបស់មីងហ្អេស?ថាតើមីងចង់អោយពួកគាត់ក្លាយជាមនុស្សបែបណា?តើមីងចង់អោយកូនៗមីងបានអើខំប្រឹងធ្វើអីខ្លះដើម្បីមានភាពជោគជ័យក្នុងជីវិតហ្អាសមីង?

ខៈ ចាស។

កៈ ដើម្បីអោយពួកគាត់អាចមានឱកាសស្តាប់ពាក្យផ្តែផ្តាំរបស់មីងចឹងហ្អាស?

ខៈ ចាស
ខ្ញុំផ្តាំផ្ញើទុកអោយកូនថាអោយកូនខំប្រឹងប្រែងកុំអោយថ្ងីប្រហេសកុំអោយដើលេងដើសើចអីអោយខុសពីច្បាប់អីចឹងអោយខំប្រឹងប្រែងអោយរកស៊ីអោយមានបានទុកសំរាប់តកូនចៅទៅមុខប៉ុណ្ណឹង។

កៈ ចាសអត់មានអីទៀតទេមីងណា?

ខៈ ចាសអត់មានអីទេដឹងនិយាយមេចទៀតអត់ចេះហិហិហិហិ។

កៈ
ចាសអញ្ចឹងអរគុណច្រើនមីងណាអញ្ចឹងអើខ្ញុំអស់សំនួរហើយហើយខ្ញុំពិតជាអរគុណមីងមែនទែនដែរបានចំណាយពេលដើម្បីពិភាក្សានឹងប្រាប់ខ្ញុំអំពីប្រវត្តិរបស់មីងហើយខ្ញុំដឹងថាអ្វីដែរមីងបានចែកចាយថ្ងៃហ្នឹងវានឹងជួយដល់មនុស្សជាច្រើនហើយនឹងកូនចៅរបស់មីងដើម្បីពួកគាត់អាចរៀននឹងដឹងពីជីវិតរបស់
មីងនៅពេលដែរពួកគាត់ក្រោយៗទៀតកើតមកហើយគាត់អត់ដែរស្គាល់មីងសោះប៉ុន្តែនៅពេលពួកគាត់ស្តាប់ការនិយាយនឹងការផ្តាំផ្ញើរបស់មីងគាត់នឹងសប្បាយចិត្តថាអើមីងនៅតែបារម្ភអំពីពួកគាត់ថាទោះបីជាយ៉ាងណាក៏មីងបានផ្តាំផ្ញើដល់កូនចៅមីងជាច្រើនដើម្បីគាត់ពួកគាត់អាចក្លាយជាមនុស្សល្អនឹងមានភាពជោគជ័យក្នុងជីវិតហ្អាសមីង។

ខៈ ចាស។

កៈ អញ្ចឹងអរគុណច្រើនមែនទេនមីងចាសអរគុណ។

ò